ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០១២៧ សហវ.អពជ

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៥

# សេចក្តីជូនដំណឹង

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងចំពោះ អ្នកឧកញ៉ា លោក លោកស្រី ជាអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ទាំងឡាយអោយបានជ្រាបថា : យោងតាមមាត្រា ៩៧.៧ នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិអនុវត្តវិធានការតឹងទារប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ ដែលសហគ្រាសមិនបានបង់ ។ ម្យ៉ាងទៀត មាត្រា ១០៨ នៃច្បាប់ស្តីពីសារពើពន្ធបានចែងថា "ប្រសិនបើអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសណាមួយដឹងឮ ឬមានចេតនាធ្វើអោយសហគ្រាសមិនរាយការណ៍ មិនបង់ប្រាក់ពន្ធ ឬរាយការណ៍បន្ថយនូវប្រាក់ពន្ធ ឬមិនអោយបង់ពន្ធគាត់ទុកជូនរដ្ឋបាលសារពើពន្ធ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករទាំងនោះ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ ដែលត្រូវបង់" ។

កន្លងមក មានសហគ្រាសមួយចំនួន ទោះបីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការអំពាវនាវអោយមកទូទាត់បំណុលពន្ធតាមវិធានការទន់ភ្លន់ក៏ដោយ. ក៏សហគ្រាស ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ទាំងនោះនៅព្រងើយកន្តើយមិនព្រមមកបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ ដែលសហគ្រាសជំពាក់នៅឡើយ ។ ជាថ្មីម្តងទៀត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមអញ្ជើញអ្នកឧកញ៉ា លោក លោកស្រី ជាអភិបាល ឬជាបណ្ណាធិការ ឬជាកម្មសិទ្ធិករសហគ្រាស ប្រញាប់មកធ្វើការទូទាត់បំណុលពន្ធអោយបានគ្រប់ចំនួន ចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងធ្វើការទាក់ទង និងបន្តទំនាក់ទំនងជាបៀងហ្វូតជាមួយស្ថាប័ន អង្គភាពនានា បន្តដាក់បទបញ្ជាអោយនាយកដ្ឋានទាំងឡាយដែលចំណុះខ្លួន ដើម្បីយកវិធានការតឹងទារចំពោះក្រុមហ៊ុន ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ដែលមិនបានបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ តាមការតំរូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ ទោះជាអភិបាលនោះ ឬបណ្ណាធិការនោះ ឬកម្មសិទ្ធិករនោះ ទទួលខុសត្រូវ ឬគ្រប់គ្រងក្រុមហ៊ុនណាមួយទៀត ដែលមិនមានការជំពាក់ក៏ដោយ ។ វិធានការតឹងទារមានដូចខាងក្រោម :

១- កាត់យកប្រាក់ក្នុងចំនួនដែលមិនលើសពីបំណុលពន្ធមុនពេលបើកទូទាត់ប្រាក់ខ្ចី ប្រាក់ឈ្នួល ប្រាក់ថ្លៃទិញទំនិញ ឬសេវាដែលស្ថាប័នរដ្ឋ ឬអង្គភាពរដ្ឋនានា ត្រូវសងអោយក្រុមហ៊ុន ឬត្រូវសងអោយអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករនៃសហគ្រាស ដែលមានជំពាក់បំណុលពន្ធ ។

២- មិនអនុញ្ញាតអោយក្រុមហ៊ុន ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករនៃសហគ្រាសដែលជំពាក់បំណុលពន្ធ ចូលរួមក្នុងការដេញថ្លៃផ្គត់ផ្គង់ទំនិញ ឬសេវានានា ឬចុះបញ្ជីធ្វើសកម្មភាពណាមួយ ដូចជាបង្កើតក្រុមហ៊ុនថ្មី ឬសកម្មភាពវិនិយោគ ជួលទ្រព្យសម្បត្តិរដ្ឋ... ជាដើម ។

៣- ទុកជាមោឃៈនូវលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណផ្សេងៗ ដែលអនុញ្ញាតអោយក្រុមហ៊ុន ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករនៃសហគ្រាសជំពាក់បំណុលពន្ធរដ្ឋ អនុវត្តសកម្មភាពណាមួយ ។

៤- ឃាត់ទុកគណនីធនាគារ

៥- រឹបអូសទ្រព្យសម្បត្តិក្នុងចំនួនមួយមិនលើសពីបំណុលពន្ធ និងចំណាយក្នុងការប្រមូលពន្ធ ក្នុងនោះរួមមានទាំងការហាមឃាត់ការផ្ទេរសិទ្ធិ ឬកម្មសិទ្ធិទ្រព្យសម្បត្តិរបស់អ្នកជំពាក់ពន្ធផង ។

ដូចនេះ ដើម្បីជៀសវាងនូវផលវិបាកដែលកើតឡើងជាយថាហេតុចំពោះក្រុមហ៊ុន ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស នៅពេលមានការអនុវត្តន៍វិធានការតឹងទារនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជឿជាក់ថា អ្នកឧកញ៉ា លោក លោកស្រី ជាអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស មុខជានឹងស្ម័គ្រចិត្តអញ្ជើញមកទូទាត់បំណុលពន្ធភ្លាម ។ ក្នុងករណីចង់ដឹងអំពីពត៌មានផ្សេងៗទាក់ទងនឹងបំណុលពន្ធ ឬវិធានការលំអិតដែលនឹងត្រូវអនុវត្តសំរាប់វិធានការតឹងទារបំណុលពន្ធនេះ សូមទាក់ទងទូរស័ព្ទលេខ ០១២ ៦២១ ៦២៩, ០១២ ៨៣៥ ៩៦៣ និង ០១២ ៤៩៤ ៩៥៩ ឬទំនាក់ទំនងផ្ទាល់ជាមួយផ្នែកសេវាអ្នកជាប់ពន្ធនៃការិយាល័យប្រមូលពន្ធតាមបេបពិត និងការិយាល័យតឹងទារបំណុលពន្ធ នៃនាយកដ្ឋានពន្ធដាររាល់ម៉ោងធ្វើការ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់